**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ២១ /២០០៨ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០០៨

## ជម្រាបមក

## ឯកឧត្តមប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**កម្មវត្ថុ** : ការបញ្ចប់ការដោះស្រាយបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

**យោង** : មាត្រា ១១៤ និង មាត្រា ១១៧ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបជូនដំណឹងដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រាបថា ក្រុមប្រឹក្សាធម្មនុញ្ញបានដោះស្រាយជាស្ថាពរនូវពាក្យបណ្តឹងរបស់គណបក្សនយោបាយនានាដែលបានប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រកាសលទ្ធផលបណ្តោះអាសន្ននៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០០៨ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមប្រធានជ្រាបជាព័ត៌មាន និង ចាត់ចែងអនុវត្តបន្តតាមភារកិច្ចដែលបានកំណត់ក្នុងច្បាប់ ។

សូមឯកឧត្តមប្រធានទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**